**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-May-2011, 08:35
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

## សំណើរបស់លោក អៀង សារី សុំឲ្យដាក់បន្ថែមប្រធានបទថ្មីៗសម្រាប់សវនាការនៅក្នុងកម្មវិធីសវនាការ

---

**ដាក់ជូនដោយ៖**
**សហមេធាវីការពារក្តីរបស់អ្នកស្រី អៀង សារី**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**ដាក់ជូន៖**
**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន
ចៅក្រម ធូ មណី
ចៅក្រម យ៉ា សុខន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង យូរ ឧត្តរា
ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Andrew CAYLEY

**សហមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្ដី") លោក អៀង សារី ស្នើសុំឲ្យដាក់ប្រធានបទថ្មីៗទៅក្នុងកម្មវិធីសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង។ សំណើសុំនេះត្រូវបានធ្វើឡើងជាចាំបាច់ ដោយសារការចង្អុលបង្ហាញលើកដំបូងរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការរៀបចំចាត់ចែង និងការកំណត់ពេលសវនាការទៅតាមលំដាប់លំដោយ ដែលបានលុបចោលសេចក្ដីយោងទៅនឹងប្រធានបទមួយចំនួនដែលមេធាវីការពារក្ដីដាក់ជូននោះ ត្រូវតែយកមកដោះស្រាយសម្រាប់គោលបំណងនៃបរិការណ៍ទាក់ទងនឹងការអះអាង និងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ សំណើសុំនេះក៏ពាក់ព័ន្ធដល់ការសម្រេចថាតើលោក អៀង សារី មានការទទួលខុសត្រូវណាមួយដែរ ឬអត់ផងដែរ។

## I. **សាវតារ**

១. នៅក្នុងកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ កន្លងទៅនេះ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសពី "ការចង្អុលបង្ហាញលើកដំបូងរបស់ខ្លួនទាក់ទងនឹងការរៀបចំ និងការកំណត់ទៅតាមដំដាប់លំដោយរបស់អង្គជំនុំជម្រះសាលាដំបូង"[១]។ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះបានលើកឡើងថា៖

> នៅដំណាក់កាលនេះ អង្គជំនុំជម្រះសូមគូសបញ្ជាក់ជាមុនអំពីលំដាប់លំដោយនៃការចាប់ផ្ដើមកិច្ចសវនាការ។ អង្គជំនុំជម្រះសូមជូនដំណឹងឲ្យភាគីបានដឹងអំពីចេតនារបស់អង្គជំនុំជម្រះ ក្នុងការបើកសវនាការលើអង្គសេចក្ដី ទៅតាមលំដាប់លំដោយដូចតទៅ៖ <u>**ទីមួយ**</u> អំពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ <u>**ទីពីរ**</u> អំពីតួនាទីរបស់ជនជាប់ចោទម្នាក់ៗនៅមុនការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងនៅពេលជនជាប់ចោទបានទទួលការចាត់តាំងនូវតួនាទីទាំងនេះផង <u>**ទីបី**</u> តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគាត់តាមការចាត់តាំង ក្របខ័ណ្ឌនៃសិទ្ធិអំណាចរបស់ពួកគាត់ និងខ្សែបណ្ដាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធនឹងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក និង<u>**ទីបួន**</u> គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្ដីពីបញ្ហាទាំងឡាយ ដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[២]។

---

[១] ដូចមាននៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការនេះ។ *សូមមើលផងដែរ* របៀបវារៈសម្រាប់កិច្ចប្រជុំរៀបចំសវនាការចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E9/5/1 ទំព័រ ២។

[២] ប្រតិចារឹក ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ៥២ (មានបញ្ជាក់បន្ថែម)។

២.	ការកំណត់ទៅតាមលំដាប់លំដោយនេះ ហាក់ដូចជាលុបចោលនូវប្រធានបទមួយចំនួន មុនឆ្នាំ ១៩៧៥ និងក្រោយឆ្នាំ ១៩៧៩ ដែលជាឯកសារឆ្លើយតបទៅនឹងការចោទប្រកាន់ ដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមានសារៈសំខាន់ដល់ការពិចារណាឲ្យបានត្រឹមត្រូវអំពីបទចោទ ដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ[៣]។

## II. ប្រធានបទជំនុំជម្រះក្តីដែលស្នើសុំ

### ក. មុនឆ្នាំ ១៩៧៥

៣.	ប្រធានបទទាំងឡាយមុនឆ្នាំ ១៩៧៥ ដូចមានខាងក្រោមនេះត្រូវបានលុបចោល៖

ក) វប្បធម៌ និងប្រជាសាស្ត្រនៃប្រទេសកម្ពុជា ចាប់ពីអំឡុងពេលមុនសម័យអាណានិគមរហូតដល់ឆ្នាំ ១៩៧៥។

ខ) ប្រវត្តិសាវតារ ការក្រោកបះបោរ និងគោលបំណងរបស់ក្រុមឆ្វេងនិយមកម្ពុជា រួមទាំងពួកឥស្សរៈ គណបក្សសាធារណៈរដ្ឋខ្មែរ បក្សពលករកម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជា (“CPK”)[៤]។

---

[៣] អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា ព័ត៌មានមុនឆ្នាំ ១៩៧៥ គឺពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វាមិនមានភាពច្បាស់លាស់ថាហេតុអ្វីបានជាការកំណត់តាមលំដាប់លំដោយនេះមិនមានប្រធានបទមុនឆ្នាំ ១៩៧៥ ក្រៅតែពីតួនាទីរបស់ជនជាប់ចោទម្នាក់ៗនៅមុនការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ។ ភ្ជាប់មកជាមួយនឹងដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ជូនភាគីនូវតារាងមួយជាមួយនឹងបញ្ជីនៃភស្តុតាង ដែលបានភ្ជាប់មកជាមួយនូវកថាខណ្ឌពាក់ព័ន្ធនៃដីកាដំណោះស្រាយ។ តារាងនេះ រួមមានប្រធានបទដែលមានចំណងជើងថា “បរិបទប្រវត្តិសាស្ត្រ និងជីវប្រវត្តិពាក់ព័ន្ធ មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥” (ចំណុចទី ១) “អត្ថិភាពនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជនមួយផ្នែកនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងតួនាទីរបស់ជនជាប់ចោទនៅពេលនោះ ដែលត្រូវបានចោទប្រកាន់” (ចំណុចទី ១០) និង “ស្ថានភាពនៅភ្នំពេញមុនឆ្នាំ ១៩៧៥ និងការចេញដំណើររបស់ប្រជាជនភ្នំពេញទៅកាន់គោលដៅផ្សេងៗជាលើកដំបូង ដែលត្រូវបានចោទប្រកាន់” (ចំណុចទី ១១)។ ដីកាបង្គាប់ឲ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9 ឧបសម្ព័ន្ធ ១ ទំព័រ ១។

[៤] ប្រវត្តិសាវតារ ការក្រោកបះបោរ និងគោលបំណងរបស់ក្រុមឆ្វេងនិយមកម្ពុជា រួមទាំង ពួកឥស្សរៈ គណបក្សបដិវត្តខ្មែរ បក្សពលករកម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជា អាចណាំឲ្យឈានដល់ការពិចារណាទៅលើព្រឹត្តិការណ៍ទាំងឡាយនៅក្នុងប្រទេសកម្ពុជា៖ **ក)** មុនសម័យអាណានិគម **ខ)** ក្នុងអំឡុងសម័យអាណានិគម **គ)** ក្នុងសម័យសីហនុ (១៩៥៣-១៩៧០) **ឃ)** ក្នុងសម័យលន់ នល់ (១៩៧០-១៩៧៥) រួមទាំងការបង្កើតរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK) និងរណសិរ្សរួបរួមជាតិកម្ពុជា (FUNK) និងនៅក្នុងអំឡុងយុទ្ធនាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក **ង)** ការពាក់ព័ន្ធទៅនឹងការស្វែងយល់

គ) បរិបទជុំវិញឥរិយាបថចំពោះព្រះពុទ្ធសាសនា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ("DK")។

ឃ) បរិបទជុំវិញឥរិយាបថចំពោះជនជាតិចាម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង

ង) បរិបទជុំវិញឥរិយាបថចំពោះជនជាតិវៀតណាម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៤. ប្រធានបទទាំងនេះត្រូវតែយកមកដោះស្រាយនៅក្នុងសវនាការ។ ប្រធានបទទាំងនេះ គឺជាឯកសារដែលលាតត្រដាងការពិតនៃការអះអាងទៅលើអង្គហេតុ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយថាបានផ្តល់នូវប្រវត្តិសាវតារចំពោះសហឧក្រិដ្ឋកម្មរួម[៥]។ ហេតុដូច្នេះ ប្រធានបទទាំងនេះពាក់ព័ន្ធដោយផ្ទាល់ (ក្នុងកម្រិតអប្បរមា និងជាការពិត) ដល់ការយល់ឃើញនៅក្នុងដីកាដំណោះស្រាយដែលថា លោក អៀង សារី តាមរយៈ "សកម្មភាព ឬការខកខានរបស់គាត់ (តាមរយៈសហឧក្រិដ្ឋកម្មរួម)" បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[៦]។

## ក. មុនឆ្នាំ ១៩៧៥

៥. ប្រធានបទក្រោយឆ្នាំ ១៩៧៩ ដូចខាងក្រោមនេះ ក៏ជាឯកសារភស្តុតាង និងមានសារៈសំខាន់ដើម្បីធ្វើការពិចារណាឲ្យបានត្រឹមត្រូវ ចំពោះបទចោទដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖

ក) ការទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យថាជារដ្ឋាភិបាលស្របច្បាប់ ដោយអង្គការសហប្រជាជាតិ។

---

អំពីទំនាក់ទំនងរបស់ក្រុមឆ្វេងនិយមកម្ពុជា ជាមួយប្រទេសវៀតណាមមុនឆ្នាំ ១៩៧៥ និង **ខ)** ការពាក់ព័ន្ធនឹងស្វែងយល់ពីឥរិយាបទប្រជាជននៅតាមជនបទរហូតដល់អ្នករស់នៅទីក្រុងមុនឆ្នាំ ១៩៧៥។ សរុបមក ប្រធានបទទាំងនេះអាចណាំឲ្យឈានដល់ការពិចារណាទៅលើបរិបទចំពោះឥរិយាបថរបស់ក្រុមឆ្វេងនិយមចំពោះទាហាន និងរដ្ឋការ លន់ នល់។ ប្រធានបទទាំងនេះក៏អាចនាំឲ្យឈានដល់ការពិចារណាទៅលើប្រវត្តិសាស្ត្រ និងប្រវត្តិសាវតារចំពោះចលនាមិនចូលបក្សសម្ព័ន្ធនៅក្នុងទំនាក់ទំនងអន្តរជាតិមុនឆ្នាំ ១៩៧៥។

[៥] *សូមមើល* ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ កញ្ញា២០១០ ឯកសារលេខ D427, កថាខណ្ឌ ១៨ ដល់ ៣២ និងកថាខណ្ឌ ១៥៦ ដល់ ២២០។

[៦] *ដូចខាងលើ* កថាខណ្ឌ ១៦១៤។

ខ) ចរិតលក្ខណៈរបស់រដ្ឋាភិបាល នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (“PRK”)[៧] និង

គ) ជីវប្រវត្តិភូមិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ[៨]។

៦. ប្រធានបទទាំងនេះត្រូវតែយកមកដោះស្រាយនៅក្នុងសវនាការ។ **ទីមួយ** ការស្វែងយល់ពីការទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យដោយអង្គការសហប្រជាជាតិ និងចរិតលក្ខណៈនៃរដ្ឋាភិបាលនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺសំខាន់បំផុត មិនមែនគ្រាន់តែដើម្បីលាតត្រដាងការពិតថាតើ **ក)** លោក អៀង សារី បានដឹងពីការសម្លាប់រង្គាលដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬយ៉ាងណានោះទេ និង **ខ)** ថាតើអំពើជាក់លាក់មួយចំនួនដែលបានប្រព្រឹត្តឡើងដោយអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចត្រូវបានចាត់ទុកថាវិធានការស្របច្បាប់ ដើម្បីយកមកធ្វើការការពារអធិបតេយ្យរបស់រដ្ឋ និង/ឬសន្តិសុខ (និងជាលទ្ធផល ថាតើអំពើទាំងនេះ អាចត្រូវបានយកមកសំអាងចំពោះសហឧក្រិដ្ឋកម្មរួមដែរឬយ៉ាងណានោះ) ប៉ុណ្ណោះទេ។ **ទីពីរ** ការស្វែងយល់ពីប្រវត្តិភូមិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការចាំបាច់ដើម្បីជួយឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចទៅលើទម្ងន់ដែលថា វាគួរតែស៊ីសង្វាក់គ្នាទៅនឹង៖ **ក)** ភស្តុតាង និងសក្ខីកម្មដែលបានផ្តល់ដោយបុគ្គលជាក់លាក់មួយចំនួន ដែលអាចត្រូវបានកោះហៅមកធ្វើជាសាក្សីជំនាញនៅក្នុងរឿងក្តីនេះ និង **ខ)** ចំពោះសម្ភារៈដែលទទួលបានពីក្រុមតស៊ូមតិមួយចំនួន ដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង សម្រេចទទួលយកឯកសារបែបនេះយកមកធ្វើជាភស្តុតាងឬយ៉ាងណានោះ។

---

[៧] ចរិតលក្ខណៈនៃរដ្ឋាភិបាលនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា អាចរួមមាន ការពិចារណាទៅលើព្រឹត្តិការណ៍ទាំងឡាយនៅក្នុងប្រទេសកម្ពុជា ដែលពាក់ព័ន្ធទៅនឹង **ក)** ការបង្កើតរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាជាលើកដំបូងពីឆ្នាំ ១៩៧៩ ដល់ ១៩៨០ **ខ)** សហាគមន៍នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាចាប់ពីឆ្នាំ ១៩៧៩ និង **គ)** ទំនាក់ទំនងកម្ពុជាជាមួយវៀតណាមក្រោយឆ្នាំ ១៩៧៩ និងការដកកងទ័ពវៀតណាម។

[៨] ប្រវត្តិភូមិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចនាំឲ្យឈានដល់ការវិភាគយ៉ាងល្អិតល្អន់ពី៖ **ក)** ប្រវត្តិភូមិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងអំឡុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និង ខ) ប្រវត្តិភូមិសាស្ត្របណ្តោះអាសន្ននៃរបបកម្ពុជាប្រជាធិបតេយ្យ។

## III. ឧឡារិករណ៍

៧. អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចចេញសាលក្រមរបស់ខ្លួន ដោយសំអាងទៅលើការចោទប្រកាន់ផ្អែកតាមអង្គហេតុ ដូចដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៩]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានផ្នែកមួយដែលមានចំណងជើងថា "ប្រវត្តិសាវតារ" ដែលសំដៅទៅលើអំឡុងពេលចន្លោះពីឆ្នាំ ១៩៣០ ដល់ ១៩៧៥[១០] និងផ្នែកសាវតាររបស់លោក អៀង សារី ដែលចាប់ផ្តើមពីទសវត្សរ៍ឆ្នាំ ១៩៤០[១១]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏បានសំអាងទៅលើការចោទប្រកាន់ក្រោយឆ្នាំ ១៩៧៩ នៅក្នុងផ្នែកដែលមានចំណងជើងថា "ព័ត៌មានអំពីអត្តចរិត"[១២]។ ជាក់ស្តែង ក.ស.ច.ស បានចាត់ទុកថា ព័ត៌មាននេះជាប់ទាក់ទងទៅនឹងការពិចារណារបស់ខ្លួនដើម្បីបញ្ជូនលោក អៀង សារី ទៅជំនុំជម្រះ។ តាមពិតទៅ នៅទូទាំងកិច្ចស៊ើបសួរ ក.ស.ច.ស បានទទួលយកសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដែលពាក់ព័ន្ធនឹងអំឡុងពេលមុនយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[១៣]។ ក.ស.ច.ស ក៏បានសំអាងទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ICTR) ដែលបានសម្រេចថា អំពើទាំងឡាយដែលបានប្រព្រឹត្តមុនយុត្តាធិការពេលវេលា អាចត្រូវបានយកមកជាសំអាង ក្នុងករណីដែលភស្តុតាងបែបនោះមានបំណង៖ "បង្ហាញពីបរិបទដែលបានកើតឡើង បង្កើតបានជាធាតុផ្សំ (ជាពិសេស ចេតនាឧក្រិដ្ឋ) នៃអំពីព្រហ្មទណ្ឌដែលកើតឡើងនៅក្នុង [យុត្តាធិការពេលវេលា] និងបង្ហាញឲ្យឃើញនូវទ្រង់ទ្រាយនៃអំពើមួយដែលបានគិតទុកជាមុន"[១៤]។

---

[៩] វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។

[១០] ដីកាដំណោះស្រាយ ភាគ I ផ្នែក I។ សាវតារប្រវត្តិសាស្ត្រ។

[១១] *ដូចជើងទំព័រខាងលើ* ភាគ I ផ្នែក IX។ សាវតារប្រវត្តិសាស្ត្រ។

[១២] *ដូចជើងទំព័រខាងលើ* ភាគ 4។

[១៣] *សូមមើល* ដីកាសម្រេចអំពីសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ឯកសារលេខ D153, D172, D174, D178 និង D284 ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ឯកសារលេខ D300 ។

[១៤] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៩ ដកស្រង់ពីរឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង* *Nahimana និងអ្នកផ្សេងទៀត*, សំណុំរឿង ICTR-99-52-A សាលដីកា ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣១៥។ *សូមមើលផងដែរ រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង* *Rwamakuba* សំណុំរឿង , ICTR-98-44C-T សាលក្រម ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៨៖

៨. ក.ស.ព ក៏បានពិចារណាផងដែរថា ប្រធានបទមុនឆ្នាំ ១៩៧៥ និងក្រោយឆ្នាំ ១៩៧៩ ពាក់ព័ន្ធនឹងបទចោទដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ នៅក្នុងសំណុំរឿង ០០១ ក.ស.ព បានលើកឡើងថា "លោក លោកស្រីដឹងអំពីយុត្តាធិការរបស់សាលាក្តីនេះហើយ គឺយុត្តាធិការផ្នែកច្បាប់ យុត្តាធិការលើរូបបុគ្គល និងយុត្តាធិការពេលវេលា។ លោក លោកស្រីក៏ដឹងហើយថា <u>សាលាជម្រះក្តីទាំងនេះមិនចាត់ការ ឬមិនរៀបរាប់បញ្ហាដែលមិនដែលកើតមាននោះទេ</u> ជាពិសេសអ្នកដែលពាក់ព័ន្ធនៅក្នុងសាលាជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិទាំងនោះតែម្តង"[១៥]។

៩. នៅក្នុងសវនាការនាពេលថ្មីៗស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ក្នុងសំណុំរឿង ០០២ លោក Dale Lysak ដែលជាជំនួយការសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា៖

> នាពេលនេះ ខ្ញុំសូមធ្វើការកត់សម្គាល់នូវមូលដ្ឋានអង្គហេតុសំខាន់ពីរ ក្នុងចំណោមមូលដ្ឋានអង្គហេតុសំខាន់ៗជាច្រើនដែលបង្ហាញហេតុផលគួរឲ្យជឿជាក់បានថា លោក អៀង សារី បានប្រព្រឹត្តបទល្មើសទាំងនេះ។ ទីមួយ ជនជាប់ចោទគឺជាសមាជិកស្ថានិកម្នាក់នៃបក្សកុម្មុយនីស្តកម្ពុជា ...។ ក្នុងខែ កញ្ញា ឆ្នាំ ១៩៦០ ជនជាប់ចោទជាតំណាងម្នាក់ក្នុងចំណោមតំណាងចំនួន ២០ នាក់ដែលបានជួបប្រជុំគ្នាជាសម្ងាត់នៅទីស្នាក់ការកម្មករនៅឯស្ថានីយ៍អយស្ម័យាន ហើយបានបង្កើតមាគ៌ា និងគោលនយោបាយបក្ស រួមទាំងបានធ្វើសេចក្តីសម្រេចឲ្យប្រើប្រាស់អំពើហិង្សាដើម្បីកម្ចាត់ខ្មាំងសត្រូវរបស់បក្ស។ ក្នុងសមាជបក្សលើកទីមួយនេះ លោក អៀង សារី ត្រូវបានបោះឆ្នោតជ្រើសរើសជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាសមាជិកត្រៀមនៃគណៈកម្មាធិការអចិន្ត្រៃយ៍។ គាត់បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍ នៅឯសមាជបក្សលើកទីពីរក្នុងខែ កុម្ភៈ ឆ្នាំ ១៩៦៣ ... [១៦]។

១០. ក.ស.ព ក៏បានដាក់បញ្ចូលផ្នែកទាំងស្រុងនៃដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនដែលពាក់ព័ន្ធនឹង "អំឡុង

---

"ភស្តុតាងនៃព្រឹត្តិការណ៍ដែលកើតមុន [យុត្តាធិការពេលវេលារបស់តុលាការ, ICTR] ដែលអាចបង្កើតបានជា "ទ្រង់ទ្រាយ គំរូ ឬអំពើជាប្រព័ន្ធដោយជនជាប់ចោទ" ឬផ្តល់នូវ<u>បរិបទ ឬ ប្រវត្តិសាវតារ</u>ចំពោះបទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់តុលាការនេះ គឺ ... អាចទទួលយកបាន" (មានបញ្ជាក់បន្ថែម)។

[១៥] *សំណុំរឿងរបស់ កាំង ហ្កេកអ៊ាវ* លេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D228/4.3.1 ទំព័រ ៧៨ (មានបញ្ជាក់បន្ថែម) *សូមមើលផងដែរ* ទំព័រ ៧៩-៨០។

[១៦] ប្រតិចារឹក ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៣២។

ពេលក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ”[១៧]។ ក.ស.ព បានលើកឡើងថា ផ្នែកទាំងនេះគឺជាប់ពាក់ព័ន្ធគ្នា ព្រោះផ្នែកទាំងនេះ “បង្ហាញពីទ្រង់ទ្រាយនៃអំពើស៊ីសង្វាក់គ្នា [និងដោយសារសកម្មភាពរបស់ជនជាប់ចោទ] នៅក្រោយការដកហូតអំណាចរបស់បក្សកុម្មុនីយស្តកម្ពុជា ជួយពង្រឹងដល់ភស្តុតាងនៃការចូលរួមប្រព្រឹត្ត និងចេតនាឧក្រិដ្ឋរបស់គាត់ ក្នុងអំឡុងពេលដែលស្ថិតក្រោមកិច្ចស៊ើបសួរ”[១៨]។

## IV. **សេចក្តីសន្និដ្ឋាន និងសំណូមពរ**

១១. ប្រធានបទដែលបានស្នើសុំនេះ គឺជាប់ពាក់ព័ន្ធ និងមានសារៈសំខាន់សម្រាប់ការពិចារណាអំពីការពិតចំពោះការចោទប្រកាន់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដូចដែល ក.ស.ព ទទួលស្គាល់ហើយថា អំពីទាំងឡាយណាដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយដែលពិតជាកើតមានមែន គឺមិនកើតឡើងដោយគ្មានអ្វីពាក់ព័ន្ធនោះទេ។ ប្រធានបទដែលបានស្នើសុំ គឺជាការចាំបាច់ដើម្បីលាតត្រដាងពីភាពសត្យានុម័ត និងសច្ចភាពនៃអំពើដែលបានចោទប្រកាន់ទាំងនោះ ហើយការស្នើសុំឱ្យទទួលយកប្រធានបទទាំងនេះ នឹងជួយអង្គជំនុំជម្រះសាលាដំបូងឱ្យចាត់ថ្នាក់អំពើដែលបានចោទប្រកាន់ទាំងនេះទៅក្នុងបរិបទសង្គម និងបរិបទនយោបាយរបស់អំពើទាំងនេះ។ លុះណាតែធ្វើបែបនេះ ទើបអង្គជំនុំជម្រះសាលាដំបូងនឹងអាចពិចារណា ថាតើអំពើទាំងនេះចូលរួមចំណែកនៅក្នុងផែនការឧក្រិដ្ឋរួម ឬនៅក្នុងអំពើមួយ ឬនៅក្នុងការធ្វេសប្រហែសដែលលោក អៀង សារី មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលបានឬអត់បាន។ ប្រធានបទទាំងនេះត្រូវតែយកមកដោះស្រាយនៅក្នុងសវនាការ។

**អាស្រ័យដោយ** មូលហេតុដូចដែលបានលើកឡើងខាងលើនេះ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពឱ្យអង្គជំនុំជម្រះសាលាដំបូងដាក់បន្ថែមប្រធានបទដូចខាងក្រោម ទៅក្នុងកម្មវិធីសវនាការ៖

ក) វប្បធម៌ និងប្រជាសាស្ត្រនៃប្រទេសកម្ពុជា ចាប់ពីអំឡុងពេលមុនសម័យអាណានិគមរហូតដល់ឆ្នាំ ១៩៧៥។

ខ) ប្រវត្តិសាវតារ ការក្រោកបះបោរ និងគោលបំណងរបស់ក្រុមឆ្វេងនិយមកម្ពុជា រួមទាំង

---

[១៧] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D390 កថាខណ្ឌ ៩៤៩ ដល់ ៩៩៦ កថាខណ្ឌ ១០៣៦ ដល់ ១០៤២ កថាខណ្ឌ ១១២៩ ដល់ ១១៤៨ កថាខណ្ឌ ១២០៦ ដល់ ១២១៦។

[១៨] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៩៤៩ កថាខណ្ឌ ១០៣៦ កថាខណ្ឌ ១១២៩ និងកថាខណ្ឌ ១២០៦។

ពួកឥស្សរៈ គណបក្សសាធារណៈរដ្ឋខ្មែរ បក្សពលករកម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជា[១៩]។

គ) បរិបទជុំវិញឥរិយាបថចំពោះព្រះពុទ្ធសាសនា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

ឃ) បរិបទជុំវិញឥរិយាបថចំពោះជនជាតិចាម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង

ង) ការទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យថាជារដ្ឋាភិបាលស្របច្បាប់ ដោយអង្គការសហប្រជាជាតិ។

ច) ចរិតលក្ខណៈរបស់រដ្ឋាភិបាល នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា[២០] និង

ឆ) ជីវប្រវត្តិភូមិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ[២១]។

សូមលោកចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើសុំនេះដោយក្តីគោរព។

---

[១៩] ប្រវត្តិសាវតារ ការក្រោកបះបោរ និងគោលបំណងរបស់ក្រុមឆ្វេងនិយមកម្ពុជា រួមទាំង ពួកឥស្សរៈ គណបក្សសាធារណៈរដ្ឋខ្មែរ បក្សពលករកម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជា អាចនាំឱ្យឈានដល់ការពិចារណាទៅលើព្រឹត្តិការណ៍ទាំងឡាយនៅក្នុងប្រទេសកម្ពុជា៖ **ក)** មុនសម័យអាណានិគម **ខ)** ក្នុងអំឡុងសម័យអាណានិគម **គ)** ក្នុងសម័យសីហនុ (១៩៥៣-១៩៧០) **ឃ)** ក្នុងសម័យ លន់ នល់ (១៩៧០-១៩៧៥) រួមទាំងការបង្កើតរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK) និងរណសិរ្សរួបរួមជាតិកម្ពុជា (FUNK) និងនៅក្នុងអំឡុងយុទ្ធនាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក **ង)** ការពាក់ព័ន្ធទៅនឹងការស្វែងយល់អំពីទំនាក់ទំនងរបស់ក្រុមឆ្វេងនិយមកម្ពុជា ជាមួយប្រទេសវៀតណាមមុនឆ្នាំ ១៩៧៥ និង **ច)** ការពាក់ព័ន្ធនឹងស្វែងយល់ពីឥរិយាបទប្រជាជននៅតាមជនបទរហូតដល់អ្នករស់នៅទីក្រុងមុនឆ្នាំ ១៩៧៥។ សរុបមក ប្រធានបទទាំងនេះអាចនាំឱ្យឈានដល់ការពិចារណាទៅលើបរិបទចំពោះឥរិយាបថរបស់ក្រុមឆ្វេងនិយមចំពោះទាហាន និងរដ្ឋការ លន់ នល់។ ប្រធានបទទាំងនេះក៏អាចនាំឱ្យឈានដល់ការពិចារណាទៅលើប្រវត្តិសាស្ត្រ និងប្រវត្តិសាវតារចំពោះចលនាមិនចូលបក្សសម្ព័ន្ធនៅក្នុងទំនាក់ទំនងអន្តរជាតិមុនឆ្នាំ ១៩៧៥។

[២០] ចរិតលក្ខណៈនៃរដ្ឋាភិបាលនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា អាចរួមមាន ការពិចារណាទៅលើព្រឹត្តិការណ៍ទាំងឡាយនៅក្នុងប្រទេសកម្ពុជា ដែលពាក់ព័ន្ធទៅនឹង **ក)** ការបង្កើតរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាជាលើកដំបូងពីឆ្នាំ ១៩៧៩ ដល់ ១៩៨០ **ខ)** សហគមន៍នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាចាប់ពីឆ្នាំ ១៩៧៩ និង **គ)** ទំនាក់ទំនងកម្ពុជាជាមួយវៀតណាមក្រោយឆ្នាំ ១៩៧៩ និងការដកកងទ័ពវៀតណាម។

[២១] ប្រវត្តិភូមិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចនាំឱ្យឈានដល់ការវិភាគយ៉ាងល្អិតល្អន់ពី៖ **ក)** ប្រវត្តិភូមិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងអំឡុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និង ខ) ប្រវត្តិភូមិសាស្ត្រសហកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៣** ខែ**ឧសភា** ឆ្នាំ**២០១១**

សហមេធាវីការពារក្ដីរបស់លោក **អៀង សារី**

| | |
|---|---|
| **អាង ឧត្តម** | **Michael G. KARNAVAS** |